Massachusetts Department of
ELEMENTARY & SECONDARY
EDUCATION

# Spring 2011 MEPA Parent/Guardian Report
# [MEPA និទាឃរដូវ ឆ្នាំ 2011 របាយការណ៍សម្រាប់មាតាបិតា/អ្នកអាណាព្យាបាល]

| | |
|---|---|
| **Name [ឈ្មោះ] ៖** | **SASID [លេខអត្តសញ្ញាណសិស្សចាត់តាំងដោយរដ្ឋ] ៖** |
| **School [សាលារៀន] ៖** | **Grade [ថ្នាក់] ៖** |
| **District [មណ្ឌល] ៖** | **Date of Birth [ថ្ងៃខែឆ្នាំកំណើត] ៖** |

## លិខិតពីនាយកគណៈកម្មាធិការ

មាតាបិតា ឬអ្នកអាណាព្យាបាលជាទីគោរព

និទាឃរដូវមុន កូនរបស់អ្នកបានប្រឡង Massachusetts English Proficiency Assessment (MEPA) [ការប៉ាន់ប្រមាណផ្នែក**ជំនាញភាសាអង់គ្លេស** រដ្ឋ Massachusetts] ដែលត្រូវបានបង្កើតឡើងដើម្បីវាស់វែងជំនាញភាសាអង់គ្លេស របស់កូនអ្នក ។ សិស្សដែលជា English language learner (ELL) [អ្នកសិក្សាភាសាអង់គ្លេស] ទាំងអស់ត្រូវប្រឡង MEPA ។ ច្បាប់តម្រូវឲ្យ សាលា បង្រៀនភាសាអង់គ្លេស ដល់សិស្សានុសិស្សដែល limited English proficient (LEP) [ផ្នែកជំនាញភាសាអង់គ្លេសមានកំរិត] ។ វាជាគោលបំណងរបស់យើងដើម្បីធានាថាសិស្ស ភាសាអង់គ្លេសអាចមានលទ្ធភាពទំនាក់ទំនងយ៉ាងមានប្រសិទ្ធិភាពជាភាសាអង់គ្លេស ។

របាយការណ៍នេះបង្ហាញលទ្ធផលរបស់កូនអ្នកនៅនិទាឃរដូវឆ្នាំ 2011 នៃការធ្វើតេស្ត MEPA លើការអាន ការសរសេរ ការស្តាប់ និងការនិយាយ ហើយផ្តល់ពិន្ទុរួម និងកំរិតធ្វើបាន ។ ប្រសិនបើ កូនអ្នកត្រូវបាន គេប៉ាន់ប្រមាណក្នុងឆ្នាំ 2010 ផងដែរនោះ យើងខ្ញុំ សង្ឃឹមថាអ្នកនឹងមើលឃើញការរីកចំរើនក្នុងលទ្ធផលពីឆ្នាំមុនមក ដល់ឆ្នាំនេះ ។ ព័ត៌មានក្នុងរបាយការណ៍នេះនឹងជួយអ្នកយល់ដឹង កម្មវិធី MEPA និងហេតុផលដែលថាហេតុបានជាវាសំខាន់ដើម្បី ធ្វើការប្រឡងអ្នករៀនភាសាអង់គ្លេសជាច្រើន។

សូមមេត្តាមកជួបលោកគ្រូ អ្នកគ្រូ របស់កូនអ្នក ដើម្បី ពិភាក្សា ពីលទ្ធផលនិងកំណត់វិធីដែលអ្នកអាចជួយគាំទ្រការអប់រំ របស់កូនអ្នក ។ ការចូលរួមពាក់ព័ន្ធរបស់អ្នកសំខាន់ណាស់ ក្នុង ការជួយកូនអ្នកអោយចេះភាសាអង់គ្លេសបានច្បាស់លាស់ និងមានជោគជ័យក្នុងសាលារៀន ។

ដោយក្តីរាប់អានដ៏ស្មោះអំពីខ្ញុំ

Mitchell D. Chester, Ed.D.
បេសកជននៃការអប់រំបឋមសិក្សានិងមធ្យមសិក្សា

## តើ MEPA គឺជាអ្វី?

Massachusetts English Proficiency Assessment – MEPA [ការប៉ាន់ ប្រមាណផ្នែកជំនាញភាសាអង់គ្លេសរដ្ឋ Massachusetts] គឺជា ការប្រឡងទូទាំងរដ្ឋដែលវាស់វែងការធ្វើបាននៃសិស្ស ដែលផ្នែកជំនាញភាសាអង់គ្លេសរបស់គេនៅមានកំរិត និងការរីកចំរើន ដែលពួកគេកំពុងធ្វើឆ្ពោះទៅរក ភាពជំនាញក្នុង ភាសាអង់គ្លេស ។ MEPA ផ្សំឡើងដោយតេស្តចំនួនពីរ ។

- Massachusetts English Proficiency Assessment-Reading/Writing – MEPA-R/W [ការប៉ាន់ប្រមាណផ្នែកជំនាញ ភាសាអង់គ្លេសរដ្ឋ Massachusetts ជំនាញ អាន និងសរសេរ] គឺជាការប្រឡងដោយប្រើក្រដាស និងខ្មៅដៃ ឬតាមបែបអនឡាញដែលវាស់វែងជំនាញក្នុងការអាន និងការសរសេរ របស់សិស្ស ។
- Massachusetts English Language Assessment-Oral – MELA-O [ការប៉ាន់ប្រមាណផ្នែកជំនាញភាសាអង់គ្លេសរដ្ឋ Massachusetts ជំនាញនិយាយផ្ទាល់មាត់] គឺជាការប៉ាន់ប្រមាណការស្តាប់ និង និយាយផ្អែកលើការសង្កេត និងការអោយចំណាត់ថ្នាក់សិស្ស នីមួយ ៗ ក្នុងអំឡុងសកម្មភាពធម្មតានៅក្នុងថ្នាក់ដោយអ្នករៀបចំការប្រឡង MELA-O ដែលបានទទួលការបណ្តុះបណ្តាលច្បាស់ លាស់ និងមានសមត្ថភាពពេញលេញ ដោយប្រើតារាងដាក់ពិន្ទុ MELA-O ។

ទាំងពិន្ទុ លើវិញ្ញាសា MEPA-R/W និង MELA-O គឺត្រូវយកមកបូក បញ្ចូលគ្នា ដើម្បីកំណត់ពិន្ទុរួមមួយសំរាប់សិស្សម្នាក់ៗ ។ មាន តែសិស្សទាំងឡាយណាដែលបានចូលប្រឡងក្នុងវិញ្ញាសារ ទាំងពីរ គឺវិញ្ញាសារ MEPA-R/W និង MELA-O ទេដែលនឹងទទួលបានពិន្ទុ MEPA សរុបរួម ។

### តើអ្នកណាអាចប្រឡង MEPA?

សិស្សានុសិស្ស ដែលភាពស្ទាត់ជំនាញភាសាអង់គ្លេសរបស់គេនៅមានកំរិត ក្នុងមត្តេយ្យសាលា ដល់ ថ្នាក់ទី 12 គឺតំរូវ អោយចូលប្រឡង MEPA ។ ការលើកលែងមានតែសំរាប់សិស្ស ដែលពិការសោតវិញ្ញាណ សិស្សដែលមានការពិបាកក្នុងការស្តាប់ សិស្សដែលត្រូវការប្រឡងតាមបែបផ្សេងទៀត ( សំរាប់តែតេស្តការអាន និងការសរសេរ តែប៉ុណ្ណោះ ) និងសិស្សដែលត្រូវការការប្រឡងតែមិនមានទីតាំងទំនេរ ។ ការចូលរួមក្នុង MEPA ជាការតំរូវដោយ ច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ ។

## ពិន្ទុ MEPA របស់កូនអ្នក មានបង្ហាញជូន នៅទំព័រខាងក្នុងនៃរបាយការណ៍នេះ ។

សិស្សទទួលបានពិន្ទុ និងកំរិតធ្វើបានជាតួលេខ ផ្អែកលើលទ្ធផល នៃការប្រឡងដែលដាច់ចេញពីគ្នាចំពោះការអាន ការសរសេរ ការស្តាប់ និង ការនិយាយ ។ ពិន្ទុមានបែងចែកក្នុង ចន្លោះពី 400 ទៅ 550 ហើយកំរិតធ្វើបានរួមមាន *កំរិត 1 កំរិត 2 កំរិត 3 កំរិត 4 និងកំរិត 5* ។ របាយការណ៍ ក៏បង្ហាញផងដែរថា តើកូនរបស់ អ្នកមានការរីកចំរើនក្នុងការសិក្សាភាសាអង់គ្លេសដែរឬទេ ។

ដើម្បីទទួលពិន្ទុ និងកំរិតធ្វើបានសិស្សត្រូវគេប៉ាន់ប្រមាណក្នុង វិស័យ **ទាំងបួន**នៃ ការអាន ការសរសេរ ការស្តាប់និងការនិយាយ ។ ជាទូទៅ សិស្សដែលទទួលបានពិន្ទុរួមដល *កំរិត 5* អាចធ្វើកិច្ចការ សាមញ្ញជាភាសាអង់គ្លេស ក្នុងថ្នាក់បាន ហើយអាចលែងជា limited English proficient (LEP) [សិស្សដែលភាពស្ទាត់ជំនាញភាសាអង់គ្លេសនៅមានកំរិត] ទៀតហើយ ។

របាយការណ៍នេះក៏បង្ហាញផងដែរថាតើកូនរបស់អ្នកធ្វើបានល្អដល់កំរិតណាចំពោះការប្រឡង MEPA ក្នុងការអាន ការសរសេរ ការស្តាប់ និងការនិយាយ បើប្រៀបធៀបទៅនឹងសិស្សទូទៅដែល ធ្វើបាននៅ*កំរិត 5* ។ ព័ត៌មាននេះនឹងជួយ អោយអ្នក និងគ្រូរបស់កូន អ្នកកំណត់បាននូវវិស័យណាខ្លះ ដែលកូនអ្នកត្រូវការការពន្យល់ ណែនាំ និងការជ្រោមជ្រែងបន្ថែម ។

ផ្នែកមួយទៀតនៃ របាយការណ៍នេះបង្ហាញថា កូនអ្នកធ្វើបានល្អប៉ុណ្ណាក្នុង MEPA ប្រៀបធៀបនឹងសិស្សភាសាអង់គ្លេស ដទៃទៀត ដែលរៀននៅ សាលារៀនរដ្ឋ នៃរដ្ឋ Massachusetts ដែលមានរយៈពេលនៃចំនួនឆ្នាំដូចគ្នានឹងកូនអ្នក ។

## តើគេប្រើប្រាស់លទ្ធផលបានពីការប្រឡង MEPA យ៉ាងដូចម្តេច?

ពិន្ទុ MEPA ត្រូវបានគេប្រើប្រាស់ភ្ជាប់ជាមួយចំណាត់ថ្នាក់ និងពិន្ទុការប្រឡងក្នុងថ្នាក់រៀនរបស់សិស្ស ពិន្ទុ MCAS និងការសង្កេត ព្រមទាំងអនុសាសន៍របស់គ្រូដើម្បីធ្វើការសំរេចចិត្តទាក់ទងនឹងការបង្រៀន និងការចាត់ថ្នាក់ជាថ្មីសំរាប់ សិស្សនីមួយៗ ។

លទ្ធផលត្រូវគេប្រើប្រាស់ដើម្បី ៖

- វាស់វែងអំពី ជំនាញភាសាអង់គ្លេស និងការរីកចំរើនក្នុងការសិក្សា ភាសាអង់គ្លេស របស់កូនអ្នក
- ធ្វើការសំរេចចិត្តអំពីការបង្រៀននៅក្នុងថ្នាក់របស់កូនអ្នក
- សម្រេចថា តើពេលណាទើបកូនអ្នកនឹងលែងចាត់ទុកជា limited English proficient (LEP) [សិស្សដែលភាពស្ទាត់ជំនាញភាសាអង់គ្លេសនៅមានកំរិត] តទៅទៀត និង
- បង្ហាញថាតើសាលា និងមណ្ឌលទាំងឡាយ មានការរីក ចំរើនឬទេក្នុងការបង្រៀនភាសាអង់គ្លេសដល់សិស្សរៀនភាសាអង់គ្លេស ។

## តើអ្វីជា "ការរីកចំរើន"?

សិស្ស ELL ដែលបានប្រឡង MEPA និទាឃរដូវ ឆ្នាំ2011 (រួមទាំងការអាន ការសរសេរ ការស្តាប់ និងការនិយាយ) ហើយដែល បានប្រឡង MEPA នានិទាឃរដូវ ឬសរទរដូវ ឆ្នាំ 2010 ត្រូវបានឲ្យ លេខលើការរីកចំរើនរបស់ពួកគេ នាឆ្នាំនេះ ក្នុងការសិក្សាភាសា អង់គ្លេស ។ គោលបំណងនៃការឲ្យលេខនេះ គឺចង់ដឹងថា តើសិស្សមានការលូតលាស់លើជំនាញភាសាអង់គ្លេសរបស់ខ្លួនបានគ្រប់គ្រាន់ ដែលនឹងលែងត្រូវការសេវា ELL បន្តទៅទៀត ក្រោយពីចូលរៀនសាលា សរអា អស់រយៈពេលប្រាំទៅប្រាំមួយឆ្នាំ រួចមក ។

តារាងខាងក្រោម បង្ហាញពីអ្វីដែលសិស្សត្រូវការ ដើម្បីមានការ "រីកចំរើន" ក្នុងការសិក្សាភាសាអង់គ្លេស ។ កំរិតសម្រេចបានទាបបំផុត ចំនួនបួន (*កម្រិត 1–4*) ត្រូវចែកចេញជាពីរជំហាន គឺទាប និងខ្ពស់ ។ កំរិតខ្ពស់បំផុត (*កំរិត 5*) ត្រូវបែងចែកទៅជា ប្រាំជំហាន ដែលមាន 10 ចំណុច ។

**សម្រាប់សិស្សដែលបានប្រឡងក្នុងកំរិត *ដូចគ្នា* នៅនិទាឃរដូវឆ្នាំ 2011 និងឆ្នាំ 2010 ( ឧទាហរណ៍ កំរិត 5–6 ទាំងពីរឆ្នាំ ) ពិន្ទុ MEPA ឆ្នាំ 2010 ត្រូវតែមានការរីកចំរើន នៅក្នុងឆ្នាំ 2011**

| ពិន្ទុ MEPA ឆ្នាំ 2010 | តម្រូវការសម្រាប់ការរីកចំរើននៅឆ្នាំ 2011 |
|---|---|
| កំរិត 1 ទាប ទៅកំរិត 3 ទាប | ត្រូវតែឈានឡើង 2 ជំហាន |
| កំរិត 3 ខ្ពស់ទៅកំរិត 5 ខ្ពស់ | ត្រូវតែឈានឡើង 1 ជំហាន |

**សម្រាប់សិស្សដែលប្រឡងក្នុងកំរិតថ្នាក់ និទាឃរដូវ ឆ្នាំ 2011 *ខុសពី* ការប្រឡងនៅនិទាឃរដូវ ឆ្នាំ 2010 ( ឧទាហរណ៍ ប្រឡងកំរិតថ្នាក់ 5–6 នៅនិទាឃរដូវឆ្នាំ 2011 និងកំរិតថ្នាក់ 3–4 ក្នុងឆ្នាំ 2010 )**

| ពិន្ទុ MEPA ឆ្នាំ 2010 | តម្រូវការសម្រាប់ការរីកចំរើននៅឆ្នាំ 2011 |
|---|---|
| កំរិត 1 ទាបទៅកំរិត 4 ខ្ពស់ | ត្រូវតែឈានឡើង 1 ជំហាន |
| កំរិត 5 | ត្រូវតែអាចរក្សាបានក្នុងកំរិត 5 |

## បើអ្នកមានចម្ងល់ តើអ្នកគួរទាក់ទងនរណា?

| | |
|---|---|
| *តើអ្នកមានចម្ងល់អំពី MCAS និង MEPA ទេ?* | mcas@doe.mass.edu ឬហៅទូរស័ព្ទទៅសាលារៀនរបស់កូនអ្នក |
| *តើអ្នកមានចម្ងល់អំពីការបង្រៀនដល់សិស្សសិក្សាភាសាអង់គ្លេស មែនទេ?* | ell@doe.mass.edu ( ជាភាសាអង់គ្លេស អេស្បាញ ឬព័រទុយហ្កាល់ ) |

# កំរិតសម្រេចបានសរុបលើ MEPA និងពិន្ទុរបស់កូនអ្នក

នៅក្នុងរូបភាពខាងក្រោម ផ្នែកខាងលើនៃបង្គោលខ្មៅបង្ហាញ ពិន្ទុសរុបរបស់កូនអ្នកលើគ្រប់ផ្នែកនៅក្នុងការប្រឡង របស់ MEPA ។
បង្គោលប្រផេះ តូចនៅផ្នែកខាងលើនៃបង្គោលខ្មៅ បង្ហាញរបាយពិន្ទុដែលកូនអ្នកទំនងអាចបានទទួលប្រសិនបើគេបាន ចូលសាកល្បង ជាច្រើនដង ។




# អត្ថន័យកំនត់នៃកំរិតធ្វើបានក្នុងការប្រឡង

| កំរិតធ្វើបាន | ការរៀបរាប់ការធ្វើបានសរុប | អំណាន | ការសរសេរ | ការនិយាយ | ការស្តាប់ |
|---|---|---|---|---|---|
| | | សិស្សទូទៅក្នុងកំរិតនេះ: | | | |
| កំរិត 5 | សិស្សនៅកំរិត 5 អាចទំនាក់ទំនង ដ៏មានប្រសិទ្ធិភាពជាភាសាអង់គ្លេស ដោយមានកំហុសយ៉ាងតិចតួចជាទីបំផុត ។ ទំនាក់ទំនងដោយផ្ទាល់មាត់ និងដោយ ការសរសេរ មានភាពត្រឹមត្រូវ ហើយអាចយល់បាន។ | អាចអាន និងយល់បានស្ទើរតែទាំងអស់នូវអត្ថបទដែលពាក់ព័ន្ធនឹងកំរិតការសិក្សា | អាចសរសេរ និងកែសំរួលអត្ថបទដែលពាក់ព័ន្ធនឹងកំរិត ការសិក្សា | អាចនិយាយភាសាអង់គ្លេស ដោយស្ទាត់ជំនាញ | អាចយល់ភាសាអង់គ្លេស សម្រាប់និយាយបាន ស្ទើរតែទាំងអស់ |
| កំរិត 4 | សិស្សនៅ កំរិត 4 ជាទូទៅអាចនិយាយភាសាអង់គ្លេសបាន យ៉ាងស្ទាត់ជំនាញ ហើយជាធម្មតាអាចយល់បាន ។ | អាចអាន និងយល់បាន មួយភាគធំចំពោះពាក្យសាមញ្ញ តាមកំរិតការសិក្សា | អាចសរសេរប្រយោគ និងអត្ថបទខ្លីៗ តាមកំរិតការសិក្សាដោយមានកំហុសតិចតួច | អាចនិយាយភាសាអង់គ្លេស បានដោយមាន កំហុសតិចតួច | អាចយល់ភាសាអង់គ្លេស សម្រាប់និយាយបានភាគច្រើនដោយ មានការនិយាយ និងពន្យល់ឡើងវិញម្តងម្កាល |
| កំរិត 3 | សិស្សនៅកំរិត 3 អាចទំនាក់ទំនងដោយប្រើភាសាអង់គ្លេស ជាមូលដ្ឋាន ដោយជួនកាលមានកំហុសរំខានដល់ការទំនាក់ទំនង និងការយល់ដឹង ។ | អាចអាន និងយល់បាន នូវពាក្យសាមញ្ញមួយចំនួន និងអាចសម្គាល់បាន នូវអក្សរក្រមជាច្រើននៃអក្ខរក្រម តាមកំរិតការសិក្សា | អាចសរសេរបាននូវពាក្យសាមញ្ញ និងប្រយោគងាយស្រួល តាមកំរិតការសិក្សា ដោយមានកំហុសខ្លះៗ | អាចនិយាយភាសាអង់គ្លេស ដោយប្រើពាក្យសាមញ្ញៗដោយមាន កំហុសខ្លះៗ | អាចយល់បានមួយភាគធំនូវ ភាសាអង់គ្លេសសម្រាប់និយាយ យ៉ាងសាមញ្ញជាមួយនឹងការនិយាយ និងពន្យល់ឡើងវិញខ្លះៗ |
| កំរិត 2 | សិស្សនៅកំរិត 2 អាចទំនាក់ទំនងដោយប្រើភាសាអង់គ្លេស សំរាប់ សរសេរ និងនិយាយបែបងាយស្រួល ដោយមានកំហុស ដែលញយៗរំខានដល់ការទំនាក់ទំនង និងការយល់ ។ | អាចអាន និងយល់បាននូវ ពាក្យសាមញ្ញតិចតួច និងអាចសម្គាល់បាននូវ អក្សរក្រមមួយចំនួន នៃអក្ខរក្រម | អាចសរសេរបាននូវពាក្យងាយស្រួល និងតួអក្សរនៃអក្ខរក្រម មួយចំនួន ដោយនៅមាន កំហុស | អាចនិយាយភាសាអង់គ្លេស ដោយប្រើពាក្យងាយស្រួល និងឃ្លាខ្លីៗ ហើយជាធម្មតាពិបាក យល់បាននូវអត្ថន័យ | អាចយល់បាននូវពាក្យ និងឃ្លា ជាភាសាអង់គ្លេសងាយស្រួល សម្រាប់និយាយ ជាមួយនឹងការនិយាយនិងពន្យល់ឡើងវិញ ជាញឹកញាប់ |
| កំរិត 1 | សិស្សនៅកំរិត 1 មិនទាន់អាចទំនាក់ទំនងដោយប្រើភាសាអង់គ្លេសនៅឡើយ កំហុស ស្ទើរតែងតែរំខានដល់ការទំនាក់ ទំនង ។ ការយល់ត្រូវបានបង្ហាញ ដោយការមិនប្រើពាក្យតាម រយៈ ពាក្យងាយស្រួលពីរបីរបស់ភាសាអង់គ្លេស ឬ ដោយប្រើភាសាមួយដែលមិនមែនជាភាសាអង់គ្លេស ។ | អាចអានពាក្យបានតិចតួច និងអាចសម្គាល់បាននូវអក្សរក្រមតែពីរបីនៃអក្ខរក្រម | អាចអានពាក្យបានតិចតួច និងអាចសម្គាល់បាននូវអក្សរក្រមតែពីរបីនៃអក្ខរក្រម | អាចនិយាយបានដោយការប្រើពាក្យងាយស្រួលជាភាសាអង់គ្លេសចំនួនពីរបីពាក្យ ប្រកបដោយកំហុសញឹកញាប់ ហើយពិបាកយល់បានណាស់ | អាចយល់បាននូវភាសាអង់គ្លេស ក្នុងការនិយាយតិចតួ ច |

## ប្រសិនបើកូនរបស់អ្នកបានទទួលពិន្ទុ :

**ការប្រឡងនានិទាយរដ្ឋឆ្នាំ 2011 របស់កូនអ្នកប្រៀបធៀបទៅ នឹងសិស្ស ELL ផ្សេងទៀត នៅក្នុងកំរិតថ្នាក់ K–2 ដែលបាន ចុះ ឈ្មោះនៅសាលារៀនរដ្ឋ របស់រដ្ឋ Massachusetts សំរាប់រយៈពេល x ឆ្នាំ ។**




បង្គោលខ្មៅបង្ហាញភាគរយនៃសិស្សក្នុងកំរិតធ្វើបាន របស់កូនអ្នក

## បើកូនរបស់អ្នកមិនបានចូលរួម :

### ការពន្យល់ស្ថានភាពពីការមិនបានចូលរួម

ប្រសិនបើមិនមានបង្ហាញពិន្ទុសំរាប់កូនអ្នកទ ស្ថានភាពពី ការមិន បានចូលរួមគឺត្រូវផ្តល់ជំនួសអោយកំរិតដែលធ្វើបាន ដូចពន្យល់រៀបរាប់ខាងក្រោម ។

| ស្ថានភាពពីការមិនបានចូលរួម | ការពន្យល់ |
|---|---|
| អវត្តមាន - បានទទួលឯកសារបញ្ជាក់ពីគ្រូពេទ្យ | កូនអ្នកមិនបានប្រឡងដោយសារអវត្តមានដែលមានឯកសារ បញ្ជាក់ពីគ្រូពេទ្យ ។ |
| អវត្តមាន | កូនអ្នកមិនបានប្រឡងដោយសារអវត្តមានដែលមិនអាចដោះ សារបាន ឬមិនបានបំពេញការប្រឡងបានចប់សព្វគ្រប់ ។ |
| មិនបានចូលរួម | កូនអ្នកមិនបានប្រឡង សំរាប់មូលហេតុមួយក្នុង ចំណោមមូល ហេតុទាំងឡាយដូចខាងក្រោម :<br>• មិនមានវិញ្ញាសារកែតម្រូវ ដែលសំរាប់ការប្រឡង ។<br>• មិនមានការវាយតំលៃតាមបែបផ្សេងទៀត ។<br>• សិស្សដែលពិការសោតវិញ្ញាណ ឬមានការលំបាកក្នុងការស្តាប់ឮគឺ មិនតំរូវអោយចូលរួមទេ ។ |
| បានផ្ទេរ | កូនអ្នកបានផ្ទេរទៅ ឬបានផ្ទេរមកពីសាលាមួយផ្សេងទៀតក្នុងអំឡុង ពេលនៃការប្រឡង និងមិនបានចូលរួមនៅម៉ោងនៃ ការសាក ល្បងគ្រប់លើក ។ |
| ត្រូវបានធ្វើឲ្យគ្មានសុពលភាព | លទ្ធផលកូនអ្នកត្រូវបានចាត់ទុកជាមោឃៈសំរាប់ហេតុផលមួយ ចំនួនដូចខាងក្រោម :<br>• កូនអ្នកបានប្រឡង ប៉ុន្តែមិនត្រូវគេតំរូវអោយចូលរួម ។<br>• ការរំលោភគោលនយោបាយនៃការរៀបចំការប្រឡងត្រូវបានគោរយការណ៍ទៅកាន់នាយកដ្ឋានសិក្សា ។ |

### ការធ្វើសាកល្បង (✔) របស់កូនអ្នក ក្នុងនិទាយរដ្ឋ 2011 ប្រៀបធៀប ទៅនឹងកំរិតសម្រេចបានរបស់សិស្សនៅកំរិត 5*

| | ពិន្ទុរបស់កូនអ្នក : | | |
|---|---|---|---|
| | ក្រោមសិស្សកំរិត 5 | ឈានទៅរកសិស្សកំរិត 5 | នៅស្មើ ឬលើសិស្សកំរិត 5 |
| អំណាន | | | |
| ការសរសេរ | | | |
| ការស្តាប់ | | | |
| ការនិយាយ | | | |

* កំរិត 5 គឺជាពិន្ទុរបស់សិស្សដែលត្រូវបានសុំឲ្យធ្វើចំណាត់ថ្នាក់ ជាថ្មី ទៅជាសិស្សមិនមែន LEP ។

Name [ឈ្មោះ] :
SASID [លេខអត្តសញ្ញាណសិស្សចាត់តាំងដោយរដ្ឋ] :